# Vacancy Announcement

FTB
ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

## ដំណឹងជ្រើសរើសបុគ្គលិក

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) គឺជាធនាគារពាណិជ្ជក្នុងស្រុកទី១ នៅកម្ពុជាដែលទទួលបានការទុកចិត្តចាប់តាំងពីឆ្នាំ១៩៧៩ ។ ធនាគារ FTB បានផ្តល់ជូនអតិថិជននូវសេវាហិរញ្ញវត្ថុប្រកបដោយភាពជឿទុកចិត្ត និងសុវត្ថិភាពខ្ពស់ក្នុងធុរកិច្ចរបស់ខ្លួន ។ ផ្អែកលើចក្ខុវិស័យ ជាធនាគារពាណិជ្ជដែលមានការពេញចិត្តជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារ FTB ប្តេជ្ញាបន្តគាំទ្រធុរកិច្ចរបស់អតិថិជនឲ្យកាន់តែរីកចម្រើនលូតលាស់ និងផ្តល់ជូនគ្រប់បុគ្គលិកនូវឱកាសអាជីពការងារ ដែលមានស្ថិរភាពយូរអង្វែងផងដែរ ។ ធនាគារកំពុងបន្តពង្រីកនូវវិសាលភាពប្រតិបត្តិការរបស់ខ្លួន និងពង្រឹងសមត្ថភាពបុគ្គលិកដើម្បីជួយទ្រទ្រង់នូវការរីកចម្រើនប្រកបដោយចីរភាពយូរអង្វែង។ ទន្ទឹមនឹងការពង្រីកប្រតិបត្តិការនេះធនាគារយើងខ្ញុំ កំពុងស្វែងរកនូវបេក្ខភាពដែលមានគុណវុឌ្ឍិ និងឆន្ទៈខ្ពស់ ដើម្បីចូលរួមជាមួយធនាគារ FTB "**និយោជកដ៏ប្រសើរនិងឈានមុខ**" សម្រាប់មុខងារខាងក្រោម៖

### ឆ្មាំយាម ( ចំនួន ០១ នាក់ បម្រើការ នៅ ភ្នំពេញ )

ឆ្មាំយាមសន្តិសុខធនាគារត្រូវទទួលខុសត្រូវ លើការសម្របសម្រួល និងថែរក្សានូវសន្តិសុខ សណ្តាប់ធ្នាប់ជូនការិយាល័យក៏ដូចអតិថិជនរបស់ធនាគារ។

### កិច្ចការចម្បងៗ និងការទទួលខុសត្រូវ

- ថែទាំ និងរក្សានូវសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាព ជូនអតិថិជនទាំងខាងក្នុង និងខាងក្រៅ ដើម្បីផ្តល់នូវជំនឿទុកចិត្តជូនអតិថិជន ក៏ដូចសាធារណជន
- រៀបចំសម្រួលចំណតចេញ-ចូល ជូនអតិថិជនទាំងខាងក្នុង និងខាងក្រៅ របស់ធនាគារ ឲ្យមានរៀបរបប តាមលក្ខណៈបច្ចេកទេស
- សម្រួលចំណតចេញ-ចូល និងធ្វើចរាចរណ៍ ឲ្យបានទាន់ពេលវេលា ធានាបាននូវភាពមិនកកស្ទះចរាចរណ៍ នៅមុខការិយាល័យ
- ជួយរក្សា និងថែទាំឧបករណ៍-សម្ភារ និងសារពើភ័ណ្ឌទាំងអស់របស់ការិយាល័យធនាគារ ដោយធានាបាននូវដំណើរការល្អ ដើម្បីបម្រើជូនអតិថិជន
- ជួយសម្រួល និងលើកដាក់ឧបករណ៍-សម្ភារ ឯកសារ និងកិច្ចការបម្រើប្រតិបត្តិការប្រចាំថ្ងៃ របស់ធនាគារ ក៏ដូចអតិថិជនដែលមកកាន់ការិយាល័យធនាគារ ដើម្បីធានាបាននូវសន្តិសុខ សុវត្ថិភាព និងការបម្រើល្អ
- ទទួលស្វាគមន៍ រាក់ទាក់ជូនអតិថិជនចេញ-ចូល និងចង្អុលបង្ហាញឆ្ពោះទៅកាន់កន្លែងបម្រើតាមតម្រូវការ ជូនអតិថិជន ប្រកបដោយភាពរួសរាយ រាក់ទាក់ និងវិជ្ជាជីវៈខ្ពស់
- បម្រើកិច្ចការផ្សេងៗទៀត ដែលពាក់ព័ន្ធក្នុងតួនាទី ជូនអតិថិជន ដែលអញ្ជើញមកដល់ការិយាល័យធនាគារ ។

### លក្ខណសម្បត្តិ និងបទពិសោធន៍

- យ៉ាងតិចមានសញ្ញាបត្របឋមភូមិ (សញ្ញាបត្រថ្នាក់ទី ៩ (Bac I) )
- ជានីតិជន ដែលមានសញ្ជាតិជាខ្មែរ និងចេះអាន សរសេរ ភាសាខ្មែរបានល្អ ។ ចេះភាសាអង់គ្លេស ត្រូវបានលើកទឹកចិត្ត
- មានបទពិសោធន៍ពាក់ព័ន្ធនឹងកិច្ចការសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ត្រូវបានផ្តល់អាទិភាព
- មានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការងារ និងមានការអត់ធន់ជាមួយការងារ ក៏ដូចលក្ខខណ្ឌការងាររបស់ធនាគារ
- មានលក្ខណសម្បត្តិក្នុងការប្រាស្រ័យទាក់ទងល្អ រួសរាយ រាក់ទាក់ និងមានឥរិយាបថចេះបម្រើអតិថិជន
- មានភាពស្មោះត្រង់ សុចរិតភាព អត់ធ្មត់ និងសកម្មលើការងារ
- អាចលះបង់នូវពេលវេលាផ្ទាល់ខ្លួន ដើម្បីទទួលនូវការបម្រើជូនធនាគារ និងអតិថិជន ។

### របៀបដាក់ពាក្យ

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញផ្ញើប្រវត្តិរូបសង្ខេប (មានបិទរូបថត) ជាមួយលិខិតអមជាភាសាខ្មែរ/អង់គ្លេសមកធនាគារតាមរយៈអ៊ីម៉ែល: HR@ftbbank.com ឬការិយាល័យកណ្តាល ស្ថិតនៅអគារលេខ ៣៣C-D ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ឬតាមសាខាណាមួយ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ។ មានតែបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានជាប់ក្នុងបញ្ជីសម្រាំង និងត្រូវបានទូរស័ព្ទអញ្ជើញឲ្យមកចូលសម្ភាសន៍ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទ: ០៨១ ៦៦៦ ៥៩៧ / ០៨១ ៤៤៤ ១៧៩

វិនិយោគដើម្បីអនាគត
Investing in the future

☎ : 023 862 111
E-mail: info@ftbbank.com
www.ftbbank.com
f : www.facebook.com/ftbcambodia